Washington State Department of
Labor & Industries

# សិទ្ធិរបស់អ្នកក្នុងនាមជាអ្នកធ្វើការ

**វាជាច្បាប់!**
និយោជកត្រូវតែបិទសេចក្តីជូនដំណឹងនេះនៅកន្លែងដែលនិយោជិកអាចអានវាបាន។

## ច្បាប់អំពីប្រាក់ឈ្នួល និងធ្វើការលើសម៉ោង

### អ្នកធ្វើការត្រូវតែទទួលបានប្រាក់ឈ្នួលអប្បបរមារបស់រដ្ឋវ៉ាស៊ីនតោន

- អ្នកធ្វើការភាគច្រើនដែលមានអាយុ 16 ឆ្នាំ ឬចាស់ជាងនេះ ត្រូវទទួលបានយ៉ាងហោចណាស់ប្រាក់ឈ្នួលអប្បបរមាសម្រាប់រយៈពេលធ្វើការទាំងអស់។ សូមមើល **www.Lni.wa.gov/MinWage**។
- អ្នកធ្វើការដែលមានអាយុ 14 ឬ 15 ឆ្នាំអាចទទួលបាន 85% នៃប្រាក់ឈ្នួលអប្បបរមា។
- ប្រាក់ទឹកតែមិនអាចរាប់ថាជាផ្នែកមួយនៃប្រាក់ឈ្នួលអប្បបរមាទេ។ និយោជកត្រូវតែទូទាត់ប្រាក់ទឹកតែទាំងអស់ទៅឱ្យនិយោជិត។

### ប្រាក់ឈ្នួលសម្រាប់ធ្វើការលើសម៉ោងគឺត្រូវបង់ឲ្យនៅពេលធ្វើការលើសពី 40 ទៅរ៉ាប់ម៉ោង

អ្នកធ្វើការភាគច្រើនត្រូវតែទទួលបានការបង់ប្រាក់ចំនួនមួយដង និងមួយដងកន្លះនៃអត្រាប្រាក់ឈ្នួលធម្មតារបស់ខ្លួនសម្រាប់រាល់ម៉ោងដែលបានធ្វើការលើសពី 40 ក្នុងមួយសប្តាហ៍ការងារ 7 ថ្ងៃថេរ។

## អ្នកធ្វើការត្រូវការពេលសម្រាកបរិភោគអាហារ និងសម្រាកស្ងៀម

### ពេលបរិភោគអាហារ

អ្នកធ្វើការភាគច្រើនមានសិទ្ធិទទួលបានពេលបរិភោគអាហារមិនបង់ប្រាក់ 30 នាទី ប្រសិនបើធ្វើការលើសពីប្រាំម៉ោងក្នុងមួយថ្ងៃ។ ប្រសិនបើអ្នកត្រូវតែនៅបំពេញកាតព្វកិច្ចក្នុងអំឡុងពេលបរិភោគអាហាររបស់អ្នក អ្នកត្រូវតែទទួលបានប្រាក់ឈ្នួលរយៈពេល 30 នាទី។ អ្នកធ្វើការផ្នែកកសិកម្មមានសិទ្ធិទទួលបានពេលបរិភោគអាហារគ្មានប្រាក់ឈ្នួល 30 នាទី ប្រសិនបើពួកគេធ្វើការលើសពី 11 ម៉ោងក្នុងមួយថ្ងៃ។ ស្វែងយល់បន្ថែមនៅ **www.Lni.wa.gov/workers-rights/workplace-policies/rest-breaks-meal-periods-and-schedules**។

### ពេលសម្រាក

- អ្នកធ្វើការភាគច្រើនមានសិទ្ធិទទួលបានការឈប់សម្រាកស្ងៀមមានបង់លុយរយៈពេល 10 នាទីសម្រាប់រយៈពេលបួនម៉ោងដែលធ្វើការ ហើយមិនត្រូវធ្វើការលើសពីបីម៉ោងដោយគ្មានការសំរាកនោះទេ។
- អ្នកធ្វើការផ្នែកកសិកម្មត្រូវតែមានការឈប់សម្រាកស្ងៀមមានប្រាក់ឈ្នួលរយៈពេល 10 នាទីក្នុងរយៈពេលរៀងរាល់បួនម៉ោងនៃការងារ។
- ប្រសិនបើអ្នកមានអាយុក្រោម 18 ឆ្នាំ សូមមើល “ផ្នែកក្មេងជំទង់” ខាងស្តាំ។

## លក្ខខណ្ឌនៃប្រាក់ឈ្នួល

### ថ្ងៃបើកប្រាក់ឈ្នួលធម្មតា

អ្នកធ្វើការត្រូវតែបានបង់យ៉ាងហោចណាស់ម្តងក្នុងមួយខែនៅថ្ងៃបើកប្រាក់ប្រចាំខែជាទៀងទាត់។ និយោជករបស់អ្នកត្រូវតែផ្តល់ជូនអ្នកនូវរបាយការណ៍ប្រាក់ខែដែលបង្ហាញពីចំនួនម៉ោងដែលបានធ្វើការ អត្រាប្រាក់ឈ្នួល ចំនួននៃឯកតាការងារ (ប្រសិនបើចំណែកការងារធ្វើបាន) ប្រាក់ឈ្នួលសរុប រយៈពេលបង់ និងការកាត់បន្ថយទាំងអស់ដែលត្រូវបានធ្វើឡើង។

សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងការកាត់ដោយមានសិទ្ធិអនុញ្ញាត សូមចូលទៅកាន់ **www.Lni.wa.gov/workers-rights/wages/getting-paid** រួចចុចលើ Paycheck deductions (ការកាត់ប្រាក់បៀវត្សរ៍)។

### ច្បាប់ស្តីពីឱកាស និងការទទួលបានប្រាក់ឈ្នួលស្មើភាពគ្នា

នៅក្រោមច្បាប់នេះ និយោជករបស់អ្នកត្រូវបានហាមឃាត់មិនឲ្យធ្វើការផ្តល់ប្រាក់ឈ្នួល ឬឱកាសបន្តអាជីពការងារដែលមិនស្មើភាពគ្នាដោយផ្អែកលើភេទនោះឡើយ។ អ្នកក៏មានសិទ្ធិបង្ហាញ ប្រៀបធៀប ឬពិភាក្សាអំពីប្រាក់ឈ្នួលរបស់អ្នក ឬប្រាក់ឈ្នួលរបស់និយោជិតដទៃទៀតបានផងដែរ។ និយោជិតរបស់អ្នកមិនអាចចាត់វិធានការធ្ងន់ធ្ងរណាមួយប្រឆាំងនឹងអ្នកដោយសារតែការពិភាក្សាអំពីប្រាក់ឈ្នួល ការដាក់ពាក្យបណ្តឹង ឬការអនុវត្តសិទ្ធិដែលត្រូវបានការពារផ្សេងទៀតនៅក្រោម Equal Pay and Opportunities Act (ច្បាប់ស្តីពីឱកាស និងការទទួលបានប្រាក់ឈ្នួលស្មើភាពគ្នា)នេះឡើយ។ និយោជកក៏ត្រូវបានហាមឃាត់មិនឱ្យស្នើសុំប្រាក់ឈ្នួល ឬប្រវត្តិប្រាក់ខែរបស់អ្នកដាក់ពាក្យផងដែរ លើកលែងតែក្នុងកាលៈទេសៈខ្លះ ហើយមិនអាចតម្រូវឱ្យមានប្រាក់ឈ្នួល ឬប្រវត្តិប្រាក់ខែរបស់អ្នកដាក់ពាក្យបានតាមលក្ខណៈវិនិច្ឆ័យមួយចំនួនឡើយ។ អ្នកដាក់ពាក្យសុំការងារក៏មានសិទ្ធិទទួលបានព័ត៌មានអំពីប្រាក់ខែជាក់លាក់ដែរ ប្រសិនបើនិយោជកមាននិយោជិកចាប់ពី 15 នាក់ឡើងទៅ។ ដើម្បីទទួលបានព័ត៌មានបន្ថែម ឬដើម្បីដាក់ពាក្យបណ្តឹង សូមចូលទៅកាន់គេហទំព័រ **www.Lni.wa.gov/EqualPay**។

### ផ្នែកក្មេងជំទង់ – ព័ត៌មានសម្រាប់អ្នកធ្វើការដែលមានអាយុ 14–17 ឆ្នាំ

- អាយុអប្បបរមាសម្រាប់ការងារជាទូទៅមានអាយុ 14 ឆ្នាំ ដោយមានច្បាប់ផ្សេងៗគ្នាសម្រាប់អាយុ 14–15 ឆ្នាំ និងអាយុ 16–17 ឆ្នាំ។
- និយោជកត្រូវមានលិខិតអនុញ្ញាតការងារអនីតិជនដើម្បីជួលក្មេងជំទង់។ តម្រូវការនេះត្រូវអនុវត្តចំពោះសមាជិកគ្រួសារលើកលែងតែនៅលើកសិដ្ឋានគ្រួសារ។ ក្មេងជំទង់មិនត្រូវការប័ណ្ណការងារទេ។
- ក្មេងជំទង់តម្រូវឲ្យមានទម្រង់បែបបទអនុញ្ញាតដែលបានចុះហត្ថលេខាមុនពេលពួកគេចាប់ផ្តើមធ្វើការ។ សម្រាប់ការងារនៅរដូវក្តៅ ឪពុកម្តាយត្រូវចុះហត្ថលេខាលើទម្រង់បែបបទ Parent Authorization for Summer Work (ការអនុញ្ញាតឲ្យធ្វើការនៅរដូវក្តៅពីឪពុកម្តាយ)។ ប្រសិនបើអ្នកធ្វើការក្នុងអំឡុងពេលសិក្សា ឪពុកម្តាយ និងមន្ត្រីសាលារៀនត្រូវចុះហត្ថលេខាលើទម្រង់ Parent/School Authorization (ការអនុញ្ញាតពីឪពុកម្តាយ/សាលារៀន) ។
- ការងារជាច្រើនមិនត្រូវបានអនុញ្ញាតសម្រាប់អ្នកដែលមានអាយុក្រោម 18 ឆ្នាំទេ ព្រោះពួកគេមិនមានសុវត្ថិភាព។
- ម៉ោងធ្វើការត្រូវបានកំណត់សម្រាប់មនុស្សវ័យជំទង់ដែលមានការរឹតបន្តឹងលើម៉ោងធ្វើការក្នុងអំឡុងពេលសប្តាហ៍សាលារៀន។

#### ពេលឈប់បរិភោគអាហារ និងការសម្រាកស្ងៀមសម្រាប់ក្មេងជំទង់

- ក្នុងការងារកសិកម្ម ក្មេងវ័យជំទង់គ្រប់វ័យទទួលបានពេលបរិភោគអាហារ 30 នាទីប្រសិនបើធ្វើការលើសពី 5 ម៉ោងនិងការសម្រាកបង់ប្រាក់រយៈពេល 10 នាទីក្នុងរយៈពេលបួនម៉ោងធ្វើការ។
- នៅក្នុងឧស្សាហកម្មដទៃទៀត ក្មេងវ័យជំទង់ដែលមានអាយុ 16 ឬ 17 ឆ្នាំ ត្រូវមានរយៈពេលអាហារ 30 នាទី ប្រសិនបើធ្វើការលើសពី 5 ម៉ោង ហើយការសម្រាកបង់ប្រាក់រយៈពេល 10 នាទីក្នុងរយៈពេលបួនម៉ោងដែលបានធ្វើការ។ ពួកគេត្រូវតែមានពេលឈប់សម្រាកស្ងៀមយ៉ាងហោចណាស់រៀងរាល់បីម៉ោងម្តង។
- ក្មេងជំទង់ដែលមានអាយុ 14 ឬ 15 ឆ្នាំ ត្រូវតែមានរយៈពេលទទួលទានអាហារ 30 នាទីមិនឲ្យយឺតជាងខាងចុងនៃម៉ោងទីបួនទេ ហើយរយៈពេលសម្រាកមានប្រាក់ឈ្នួលចំនួន 10 នាទីសម្រាប់រៀងរាល់ពីរម៉ោងម្តងដែលបានធ្វើការ។

ដើម្បីស្វែងយល់បន្ថែមអំពីក្មេងជំទង់នៅកន្លែងធ្វើការ៖
**www.Lni.wa.gov/TeenWorkers**, 1-866-219-7321, TeenSafety@Lni.wa.gov។

Washington State Department of Labor & Industries

# សិទ្ធិរបស់អ្នកក្នុងនាមជាអ្នកធ្វើការ

## ច្បាប់ឈប់សម្រាក

### ការឈប់សម្រាកឈឺមានប្រាក់ឈ្នួល

អ្នកធ្វើការភាគច្រើនទទួលបានការឈប់សម្រាកឈឺមានប្រាក់ឈ្នួល យ៉ាងហោចណាស់មួយម៉ោងសម្រាប់រាល់ 40 ម៉ោងដែលបានធ្វើការ។ ការឈប់សម្រាកនេះអាចត្រូវបានប្រើចាប់ពីថ្ងៃការងារទី 90។ និយោជកត្រូវផ្តល់ជូននិយោជិកនូវសេចក្តីថ្លែងការណ៍ដែលរួមមានចំនួនម៉ោងដែលបានកើនឡើង បានប្រើនិងនៅសល់នៃការឈប់សម្រាកនេះយ៉ាងហោចណាស់ម្តងក្នុងមួយខែ។ ព័ត៌មាននេះអាចត្រូវបានផ្តល់ជូននៅលើរបាយការណ៍ប្រាក់ឈ្នួលធម្មតារបស់អ្នក ឬជាការជូនដំណឹងដាច់ដោយឡែក។ អ្នកធ្វើការត្រូវបានអនុញ្ញាតឲ្យយោងរយៈពេលអប្បបរមា 40 ម៉ោងនៃការឈប់សម្រាកឈឺមានប្រាក់ឈ្នួលដែលមិនទាន់បានប្រើណាមួយទៅឆ្នាំបន្ទាប់ទៀត។ សម្រាប់ព័ត៌មានលម្អិតស្តីពីការប្រើប្រាស់ដែលមានការអនុញ្ញាត សេចក្តីលម្អិតអំពីការកើនឡើង និងសិទ្ធិទទួលបាន សូមចូលមើលគេហទំព័រ **www.Lni.wa.gov/SickLeave**។

### ច្បាប់ថែរក្សាសុខភាពគ្រួសាររដ្ឋ Washington៖ ការប្រើប្រាស់កាឈប់សម្រាកដែលមានប្រាក់ឈ្នួល ដើម្បីថែទាំគ្រួសារដែលឈឺ

និយោជិកមានសិទ្ធិប្រើជម្រើសរបស់ពួកគេចំពោះនិយោជកដែលបានផ្តល់ការឈប់សម្រាក (ឈឺ វិស្សមកាល គម្រោងពិការភាពរយៈពេលខ្លីជាក់លាក់ ឬពេលឈប់ដែលបង់ប្រាក់ឲ្យផ្សេងទៀត) ដើម្បីថែទាំ៖

- កុមារដែលមានបញ្ហាសុខភាពត្រូវការការព្យាបាល ឬការមើលការខុសត្រូវ។
- ប្តី/ប្រពន្ធ ឪពុកឬម្តាយ ឪពុកឬម្តាយក្មេក ឬជីដូនជីតាដែលមានស្ថានភាពសុខភាពធ្ងន់ធ្ងរ ឬស្ថានភាពសុខភាពបន្ទាន់ ហើយ
- កុមារពិការដែលមានអាយុ 18 ឆ្នាំ និងចាស់ជាងនេះ ដែលធ្វើឱ្យពួកគេមិនអាចថែទាំខ្លួនឯងបាន។
- សម្រាប់ព័ត៌មានបន្ថែម សូមមើល **www.Lni.wa.gov/workers-rights/leave/family-care-act**។

### ការឈប់សម្រាកសម្រាប់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ, ការបៀតបៀនផ្លូវភេទ ឬការឈ្លបតាមចាប់

ជនរងគ្រោះនិងសមាជិកគ្រួសាររបស់ពួកគេត្រូវបានអនុញ្ញាតឱ្យឈប់សម្រាកសមស្របពីការងារសម្រាប់ជំនួយផ្នែកច្បាប់ ឬការអនុវត្តច្បាប់ ការព្យាបាលវេជ្ជសាស្រ្ត ការផ្តល់ប្រឹក្សា ការផ្លាស់ប្តូរទីកន្លែង ការប្រជុំជាមួយអ្នកតស៊ូមតិជនរងគ្រោះដោយអំពើឧក្រិដ្ឋ ឬដើម្បីការពារសុវត្ថិភាពរបស់ពួកគេ។ និយោជកក៏តម្រូវឲ្យផ្តល់ជូនកន្លែងស្នាក់នៅមានសុវត្ថិភាពសមរម្យដល់ជនរងគ្រោះផងដែរ។ សម្រាប់ព័ត៌មានបន្ថែម សូមមើល **www.Lni.wa.gov/DVLeave**។

### ការឈប់សម្រាកសម្រាប់គូស្វាមីភរិយាយោធាក្នុងអំឡុងពេលដាក់ពង្រាយ

ប្តី/ប្រពន្ធ ឬដៃគូក្នុងគ្រួសារដែលបានចុះបញ្ជីរបស់បុគ្គលិកយោធាដែលបានទទួលការជូនដំណឹងដើម្បីដាក់ពង្រាយ ឬអ្នកដែលកំពុងសម្រាកពីការដាក់ពង្រាយក្នុងអំឡុងពេលជម្លោះយោធាអាចដាក់ច្បាប់ឈប់សម្រាកពីការដាក់ពង្រាយសរុបបាន 15 ថ្ងៃដោយគ្មានប្រាក់ឈ្នួល។

និយោជករបស់អ្នកនឹងមិនបណ្តេញអ្នកចេញ ឬសងសឹកអ្នកចំពោះការអនុវត្តសិទ្ធិរបស់អ្នក ឬដាក់ពាក្យបណ្តឹងទាក់ទងនឹងប្រាក់ឈ្នួលអប្បបរមា ប្រាក់ធ្វើការលើសម៉ោង ការឈប់សម្រាកឈឺមានប្រាក់ឈ្នួល ឬការឈប់សម្រាកដែលមានការការពារឡើយ។

### គ្រប់គ្រងដោយទីភ្នាក់ងារផ្សេងទៀត

**Paid Family and Medical Leave (ការឈប់សម្រាកសម្រាប់គ្រួសារនិងការព្យាបាលជំងឺដោយមានប្រាក់ឈ្នួល)** គ្រប់គ្រងដោយ Washington Employment Security Department (ក្រសួងសន្តិសុខការងាររដ្ឋ Washington)។ រដ្ឋ Washington ផ្តល់ជូននូវអត្ថប្រយោជន៍ការឈប់សម្រាកព្យាបាល និងគ្រួសារដោយមានប្រាក់ឈ្នួលដល់អ្នកធ្វើការ។ កម្មវិធីធានារ៉ាប់រងនេះទទួលបានការឧបត្ថម្ភថវិកាដោយបុព្វលាភរ៉ាប់រងដែលត្រូវបានបង់ដោយនិយោជក និងនិយោជិត។ បុគ្គលិកត្រូវបានអនុញ្ញាតឱ្យឈប់សម្រាករហូតដល់ 12 សប្តាហ៍ តាមការចាំបាច់ នៅពេលពួកគេស្វាគមន៍កូនទើបកើតថ្មីនៅក្នុងគ្រួសាររបស់ពួកគេ ត្រូវរងគ្រោះដោយជំងឺ ឬរបួសធ្ងន់ធ្ងរ ឬត្រូវការថែទាំសាច់ញាតិដែលឈឺ ឬមិនស្រួលខ្លួន និងដើម្បីចូលរួមក្នុងព្រឹត្តិការណ៍ពាក់ព័ន្ធនឹងយោធាជាក់លាក់មួយចំនួន។ ដូចដែលបានណែនាំដោយអង្គនីតិបញ្ញត្តិ ការវាយតម្លៃបុព្វលាភចាប់ផ្តើមនៅថ្ងៃទី 1 ខែមករា ឆ្នាំ 2019។ សម្រាប់ព័ត៌មានបន្ថែម សូមមើល **www.paidleave.wa.gov** ។

**ការឈប់សម្រាកពិការភាពមានផ្ទៃពោះ៖** អនុវត្តដោយ Washington State Human Rights Commission (គណៈកម្មការសិទ្ធិមនុស្សរបស់រដ្ឋ Washington) ក្រោម Washington State Law Against Discrimination ច្បាប់ប្រឆាំងនឹងការរើសអើងរដ្ឋ Washington (Washington State Law Against Discrimination, WLAD) **www.hum.wa.gov** ឬ 1-800-233-3247

**Family and Medical Leave Act (ច្បាប់ស្តីពីការឈប់សម្រាកសម្រាប់គ្រួសារនិងការព្យាបាលជំងឺ)** គ្រប់គ្រងដោយ U.S. Department of Labor (ក្រសួងការងារសហរដ្ឋអាមេរិក)។ និយោជិតដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់អាចអនុវត្តសិទ្ធិរបស់ពួកគេក្នុងការទទួលបានការឈប់សម្រាកព្យាបាល និងគ្រួសារដែលមានការការពារនៅក្រោម ច្បាប់ឈប់សម្រាកគ្រួសារ និងវេជ្ជសាស្រ្ត (Family and Medical Leave Act, FMLA) ដោយទាក់ទងទៅ ក្រសួងការងារតាម **www.dol.gov/whd/fmla** ឬ **1-866-487-9243**។

### សូមទាក់ទង L&I (ក្រសួងការងារនិងឧស្សាហកម្ម)

**ត្រូវការព័ត៌មានបន្ថែម?**
**មានសំណួរអំពីការដាក់ពាក្យបណ្តឹងអំពីសិទ្ធិអ្នកធ្វើការឬ?**

| | |
|---|---|
| អនឡាញ៖ | **www.Lni.wa.gov/workers-rights** |
| ហៅទូរស័ព្ទ៖ | 1-866-219-7321 លេខទូរស័ព្ទឥតគិតថ្លៃ |
| ទស្សនា៖ | **www.Lni.wa.gov/Offices** |
| អ៊ីមែល៖ | ESgeneral@Lni.wa.gov |

**អំពីប័ណ្ណប្រកាសកន្លែងធ្វើការដែលតម្រូវឲ្យមាន**

សូមចូលទៅ **www.Lni.wa.gov/RequiredPosters** ដើម្បីស្វែងយល់បន្ថែមអំពីប័ណ្ណប្រកាសកន្លែងការងារពី L&I និងភ្នាក់ងាររដ្ឋាភិបាលដទៃទៀត។

### ការជួញដូរមនុស្សគឺផ្ទុយនឹងច្បាប់

សម្រាប់ជំនួយជនរងគ្រោះ សូមហៅទូរស័ព្ទមក National Human Trafficking Resource Center (មជ្ឈមណ្ឌលធនធានការជួញដូរមនុស្សជាតិ)តាមលេខ 1-888-373-7888 ឬ Washington State Office of Crime Victims Advocacy (ការិយាល័យតស៊ូមតិជនរងគ្រោះដោយឧក្រិដ្ឋកម្មនៅរដ្ឋវ៉ាស៊ីនតោន)តាមលេខ 1-800-822-1067។

*ជំនួយភាសាបរទេស និងទម្រង់ផ្សេងៗសម្រាប់ជនពិការក៏មានជូនតាមការស្នើសុំផងដែរ។ ទូរសព្ទទៅលេខ 1-800-547-8367 ។ អ្នកប្រើ TDD ទូរសព្ទទៅលេខ 711 ។ L&I ជានិយោជកដែលផ្តល់ឱកាសដោយស្មើភាព។*

PUBLICATION F700-074-214 (Cambodian) [10-2021]